# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២

## ប្រទេសអូស្ត្រាលីផ្តល់វ៉ាក់សាំងសម្រាប់កុមារ ដល់ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃនេះ ប្រទេសអូស្ត្រាលីបានប្រគល់វ៉ាក់សាំង Pfizer-BioNTech សម្រាប់កុមារ អាយុ៥ឆ្នាំដល់ ១១ឆ្នាំ ចំនួន ១៩៦ ៨០០ដូស នៃចំនួនដែលនឹងប្រគល់សរុបទាំងអស់ ចំនួន ៤៨២ ៤០០ដូស ដល់ប្រទេសកម្ពុជា។

វ៉ាក់សាំងសម្រាប់កុមារនាពេលនេះ គឺជាការបន្ថែមទៅលើជំនួយ វ៉ាក់សាំង Pfizer-BioNTech ចំនួន ២,៣៥ លានដូស ទូបង្កកត្រជាក់ និងទូបង្កកត្រជាក់បំផុត សរុបទាំងអស់ចំនួន១៣៣គ្រឿង និងគ្រឿងបរិក្ខាចាំបាច់ផ្សេងៗទៀត ដែលជាជំនួយទ្វេភាគី របស់ប្រទេសអូស្ត្រាលី។ ជំនួយទាំងនេះគឺជាផ្នែកមួយនៃជំនួយអូស្ត្រាលី ដែលមានថវិកាចំនួន៣៥,៧លានដុល្លាអូស្ត្រាលី ដែលជាការប្តេជ្ញាចិត្តគ្រប់ជំហានទាំងអស់ ឆ្ពោះទៅរកយុទ្ធនាការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព ប្រសិទ្ធិភាព និងសមភាព នៅកម្ពុជា។

ឯកឧត្តម ប៉ាប្លូ កាង ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានស្វាគមន៍ការផ្តល់ជំនួយវ៉ាក់សាំងនេះ។ "ប្រទេសអូស្ត្រាលី និងប្រទេសកម្ពុជា មានទំនាក់ទំនងជាប្រវត្តិសាស្ត្រដ៏យូរអង្វែង រយៈពេល៧០ឆ្នាំ ក្នុងចំណងមិត្តភាព និងភាពជាដៃគូ។ យើងប្តេជ្ញាសហការជាមួយប្រទេសកម្ពុជា ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ រួមទាំងគោលបំណងរួមរបស់យើង ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល ជាទូទៅរបស់កម្ពុជា"។

ឯកឧត្តម ឯកអគ្គរាជ ទូតប៉ាប្លូ កាង បានបន្ថែមទៀតថា "ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍សុខាភិបាល បាននិងកំពុងឈរនៅជួរមុខ ក្នុងយុទ្ធនាការអស់រយៈកាលដ៏យូរ និងមិនចេះនឿយហត់ ដើម្បីការពារប្រជាពលរដ្ឋកម្ពុជា ហើយឥឡូវនេះ យើងមកដល់ដំណាក់កាល ដែលត្រូវសម្លឹងឆ្ពោះទៅកាន់អនាគត។ កុមារដើរតួនាទីដ៏សំខាន់សម្រាប់អនាគត ដូច្នេះវាជាការសំខាន់ណាស់ ដែលកុមារត្រូវមានសុវត្ថិភាពដើម្បី រៀនសូត្រ លេងកំសាន្ត និងធំធាត់"។

ប្រទេសអូស្ត្រាលីបន្តភាពជាដៃគូរបស់ខ្លួន ជាមួយអង្គការយូនីសេហ្វ ដែលជាដៃគូយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងតំបន់ ហើយទទួលស្គាល់នូវជំនាញបច្ចេកទេសរបស់ពួកគេ និងភាពជាដៃគូនេះ ក្នុងការជួយអោយយើងអាចសម្រេចបានក្នុងថ្ងៃនេះ។ អង្គការយូនីសេហ្វបានបង្ហាញយ៉ាងច្បាស់ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩នេះថា ពួកគេជាអ្នកដឹកនាំក្នុង កិច្ចការលទ្ធកម្ម និងការផ្តល់វ៉ាក់សាំង ជាពិសេសការបង្កើនលទ្ធភាពរបស់ប្រជាជនកម្ពុជា ដែលងាយរងគ្រោះ រួមទាំងជនដែលមានពិការភាព និងស្ត្រីមានផ្ទៃពោះ ក្នុងការទទួលបាននូវវ៉ាក់សាំងនេះ។

ជំនួយថ្មីបំផុតរបស់ប្រទេសអូស្ត្រាលីនេះ គឺជាការបន្ថែមទៅលើកិច្ចសហការរាប់ទសវត្សរ៍មកហើយ របស់យើងក្នុងវិស័យសុខាភិបាល ក្នុងនោះរួមមាន តាមរយៈការអនុវត្តគម្រោងលើកកម្ពស់សមធម៌ និងគុណភាពសុខាភិបាលនៅកម្ពុជា (គម្រោងហេកអេគីប) ដែលធ្វើការលើកកម្ពស់គុណភាពសេវាសុខាភិបាល ផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ជាង១ ៣០០ នៅទូទាំងប្រទេសកម្ពុជា។

ប្រទេសអូស្ត្រាលី នឹងបន្តឈរជាមួយកម្ពុជា ក្នុងការឆ្លើយតបនឹងជំងឺរាតត្បាតជាសកលនេះ និងរក្សាការប្តេជ្ញាចិត្តក្នុងការសហការគ្នា ដើម្បីធានាឲ្យមានសុវត្ថិភាព និងវិបុលភាព ជូនដល់ប្រជាពលរដ្ឋរបស់យើង ប្រទេសរបស់យើង និងតំបន់របស់យើង។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au